# ពិធីជ្រមុជទឹក



នៅពេលព្រះយេស៊ូយាងចេញពីពួកសាវ័ក ទ្រង់ប្រទានសេចក្តីបង្គាប់ដ៏សំខាន់មួយដល់ពួកគេ ។

*...ចូរទៅបញ្ចុះបញ្ចូលឱ្យមានសិស្សនៅគ្រប់ទាំងសាសន៍ ព្រមទាំងធ្វើបុណ្យជ្រមុជ ទឹកឱ្យ ដោយនូវក្នុងព្រះនាមព្រះវរបិតាព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ ។ ម៉ាថាយ ២៨:១៩*

អត្ថន័យដើមនៃពាក្យ «ពិធីបុណ្យជ្រមុជទឹក» មានន័យថាជ្រមុជចូល ឬអាចមានន័យថា «ជ្រលក់ចុះ» ។ ដូច្នោះហើយ បើលោកអ្នកបានរស់នៅសម័យកាលព្រះគ្រិស្ត ហើយលោកអ្នកចង់ជ្រលក់ពណ៌សំលៀកបំពាក់ បន្ទាប់ពីធ្វើរួចហើយ នោះលោកអ្នកអាចនិយាយបានថា៖ "ខ្ញុំបានជ្រលក់រួចហើយ"។ ប្រសិនជាកប៉ាល់មួយបានបុកនឹងភ្នំនៅសមុទ្រ គេអាចនិយាយបានថា កប៉ាលនោះបានលិចបាត់ទៅក្នុងទឹក រលកបានគ្របលើកប៉ាល់នោះហើយ។ នៅពេលដែលព្រះយេស៊ូទទួលពិធីជ្រមុជទឹក ទ្រង់បានយាងចុះទៅក្នុងទន្លេយ័រដាន់ ហើយបានទទួលជ្រមុជទឹកដោយលោកយ៉ូហានបាទីស្ទ *សូមមើល ម៉ាថាយ ៣:១៣-១៧* ។ ការធ្វើដូច្នោះ



ព្រះយេស៊ូបានផ្តល់នូវការគាំទ្រពីសារៈសំខាន់ នៃការធ្វើពិធីបុណ្យជ្រមុជទឹក ។

## ពិធីបុណ្យជ្រមុជទឹកនៅក្នុងសម្ពន្ធមេត្រីថ្មី

តើគុណសម្បត្តិអ្វីខ្លះ ដែលចាំបាច់សម្រាប់ពិធីបុណ្យជ្រមុជទឹក?
កិច្ចការ ២:៣៨ ______________________
កិច្ចការ ២:៤១ ______________________
កិច្ចការ ១៦:២៩-៣៣______________________

គួរកត់សម្គាល់ដែរថាពិធីបុណ្យជ្រមុជទឹក គឺមិនអាស្រ័យទៅលើថាតើយើងមានអារម្មណ៍ល្អល្អម ឬ អត់នោះឡើយ ។ ប៉ុន្តែព្រះយេស៊ូវបញ្ជាក់យ៉ាងច្បាស់ថាអ្នកត្រូវតែក្លាយជា សាវ័កម្នាក់ (ម៉ាថាយ ២៨:១៩) ហើយសាវ័ក គឺជាសិស្សដែលយកគំរូតាមគ្រូរបស់គេ ។
នៅក្នុងខយោងខាងក្រោមនេះ តើទារក ឬ អ្នកជឿដែលត្រូវទទួលបុណ្យជ្រមុជទឹក?
កិច្ចការ ៨:៣៥-៣៨ ______________________
កិច្ចការ ៩: ១៧-១៨ ______________________
កិច្ចការ ១៩: ៣-៥ ______________________

សម្រាប់អ្នកជឿ តើពិធីបុណ្យជ្រមុជទឹកគឺជា ជម្រើស ឬ ជាសេចក្តីបង្គាប់?

ម៉ាថាយ ២៨:១៩ ______________________

ប្រសិនបើលោកអ្នកចង់ក្លាយជាសាវ័ករបស់ព្រះយេស៊ូគ្រិស្ត នោះលោកអ្នកត្រូវតែធ្វើតាមអ្វីដែលព្រះអង្គបង្គាប់ ។

តើយើងគួរទទួលពិធីជ្រមុជទឹកដោយនៅក្នុងនាមអ្នកណា?
ម៉ាថាយ ២៨:១៩ ______________________

## អស់អ្នកដែលស្ទាក់ស្ទើរនៅក្នុងការទទួលពិធីជ្រមុជទឹក

តើលោកអ្នកស្ទាក់ស្ទើរក្នុងការទទួលពិធីជ្រមុជទឹកឬ? សូមមើលការជំទាស់ទូទៅមួយចំនួន ។

### ១. ខ្ញុំមិនមែនជានិកាយបាប់ទីស្ទទេ ។

វាមិនចាំបាច់ទាល់តែអ្នកជានិកាយបាប់ទីស្ទ ឬ មិនមែននោះទេ ។ ពិធីបុណ្យជ្រមុជទឹក គឺមិនមែនសម្រាប់តែអ្នកដែលនៅក្នុងនិយកាយបាប់ទីស្ទប៉ុណ្ណោះទេ។ ពិធីបុណ្យជ្រមុជទឹករបស់អ្នកមានជំនឿ គឺសម្រាប់អ្នកជឿទាំងអស់ ដោយមិនគិតពីនិកាយដែលពួកគេចូលរួមថ្វាយបង្គំនោះឡើយ ។ បទបញ្ជានៃដំណឹងល្អ គឺមិនបានកំណត់ពីក្រុមជំនុំណានោះទេ ប៉ុន្តែសម្រាប់អ្នកដែលដើរតាមព្រះគ្រិស្តទាំងអស់ ។ វាជាការត្រាស់ហៅមួយដែលមិនត្រូវបានដកចេញនោះឡើយ ។

### ២. វាមិនចាំបាច់នោះទេ ខ្ញុំក៏អាចធ្វើជាគ្រិស្តបរិស័ទដ៏ល្អម្នាក់បានដែរដោយមិនបាច់មានពិធីជ្រមុជទឹក។

ជាការពិត ពិធីជ្រមុជទឹកមិនមានសារៈសំខាន់ សំរាប់ទទួលការសង្គ្រោះនោះឡើយ *ដ្បិត គឺដោយសារព្រះគុណដែលអ្នករាល់គ្នាបានសង្គ្រោះ ដោយសារសេចក្តីជំនឿហើយសេចក្តីនោះ ក៏មិនមែនកើតពីអ្នករាល់គ្នាដែរ គឺជាអំណោយទានរបស់ព្រះវិញ ក៏មិនមែនដោយការប្រព្រឹត្តដែរ ក្រែងអ្នកណាអួតខ្លួន។ អេភេសូរ ២: ៨-៩*។ប៉ុន្តែ ការលើកឡើងនូវអ្វីដែលព្រះអម្ចាស់បានបង្គាប់ មិនមែនជាការចាំបាច់នោះទេ «ខ្ញុំក៏អាចធ្វើជាគ្រិស្តបរិស័ទល្អម្នាក់បានដែរ

ដោយមិនបាច់មានពិធីជ្រមុជទឹក» ។ គឺជារឿងមួយដ៏ហួសចិត្ត

សម្រាប់អ្នកដែលដើរតាមព្រះអង្គដែលនិយាយយ៉ាងដូច្នោះ ។

### ៣. ខ្ញុំបានទទួលពិធីជ្រមុជទឹករួចហើយ កាលនៅជាទារក ។



ពិធីជ្រមុជទឹកកាលនៅជាទារក គឺមិនមែនជាពិធីបុណ្យជ្រមុជទឹករបស់អ្នកជឿដូចដែលមាននៅក្នុងក្រុមជំនុំសម្ពន្ធមេត្រីថ្មីនោះទេ ដូច្នេះឥឡូវនេះគ្មានហេតុផលណាដែលត្រូវបដិសេធន៍ ដោយមិនព្រមធ្វើតាមព្រះគ្រិស្តនៅក្នុងផ្លូវរបស់ទ្រង់នោះឡើយ។ ពិធីបុណ្យជ្រមុជទឹកដល់ទារក បានចេញពីទំនៀមទំលាប់របស់ក្រុមជំនុំខ្លះ ។

### ៤. ការជ្រមុជដោយព្រះវិញ្ញាណបរិសុទ្ធ ជំនួសឲ្យការជ្រមុជទឹករបស់អ្នកជឿ។

មិនដូច្នោះទេ បទពិសោធន៍នៃការជ្រមុជទាំងពីរនេះត្រូវបានលើកឡើងនៅក្នុងគម្ពីរសម្ពន្ធមេត្រីថ្មី ដោយគ្មានការដកចេញណាមួយនោះឡើយ។ នៅក្នុងគម្ពីរកិច្ចការ ១០:៤០-៤៨ ។ បទគម្ពីរទាំងពីរ រៀបរាប់អំពីការជ្រមុជទឹក ហើយលោកពេត្រុសឆ្លើយថា៖ «*ចូរអ្នករាល់គ្នាប្រែចិត្តចុះ ហើយទទួល*

*បុណ្យជ្រមុជទឹកទាំងអស់គ្នា ដោយនូវព្រះនាមព្រះយេស៊ូគ្រិស្ត ប្រយោជន៍ឱ្យបានរួចពីបាប នោះអ្នករាល់គ្នានឹងទទួលព្រះអំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ*» ។ (សូមមើលបន្ថែម កិច្ចការ ២: ៣៩-៤១)

### ៥. ខ្ញុំមានអារម្មណ៍ថា ខ្ញុំមិនទាន់ត្រៀមខ្លួននៅឡើយ ខ្ញុំនឹងចាំរហូតដល់ខ្ញុំប្រាកដថាខ្ញុំអាចធ្វើបាន ។

វាពិតជាការពិបាកមួយសំរាប់គ្រិស្តបរិស័ទដែលស្មោះត្រង់ជាច្រើន។ ពួកគេបានគេចវេះពីលទ្ធភាពនៃការមិនលើកតម្កើងព្រះគ្រិស្ត បន្ទាប់ពីបានធ្វើពិធីជ្រមុជទឹកនៅក្នុងព្រះនាមរបស់ព្រះអង្គរួចមក ប៉ុន្តែការពិបាកនោះជាការយល់ខុស។ ជំនឿ មិនមែនទាល់តែយើងមើលទៅថាល្អឥតខ្ចោះដល់យើង សំរាប់ធ្វើពិធីបុណ្យជ្រមុជទឹកនោះទេ។ តើលោកប៉ូលបាន «ត្រៀមខ្លួនរួចហើយ» នៅពេលដែលលោកបានទទួលបុណ្យជ្រមុជទឹក

បីថ្ងៃបន្ទាប់ពី លោកបានប្រែចិត្ត? សូមគិតពីជីវិតកាលពីដើមរបស់លោក និងការប្រឆាំង ជំទាស់ដែលលោកប៉ូលបានធ្វើទៅលើព្រះយេស៊ូគ្រិស្ត អ្នកដែលដើរតាមទ្រង់ និងទៅលើក្រុមជំនុំដំបូង ។

## អត្ថន័យនៃពិធីបុណ្យជ្រមុជទឹក

វាជាការសំខាន់ដើម្បីយល់ពីអត្ថន័យនៃពិធីបុណ្យជ្រមុជទឹក ។

## ១. វាជាភស្តុតាងបង្ហាញជាសាធារណៈ ។

ការទទួលពិធីជ្រមុជទឹក គឺជាភស្តុតាងបង្ហាញជាសាធារណៈនៅក្នុងការប្រកាស អំពីជំនឿលើព្រះយេស៊ូ ជាព្រះអម្ចាស់ និងជាព្រះអង្គសង្គ្រោះរបស់យើង ។

តើនៅកន្លែងណាដែលលោកយ៉ូហានធ្វើពិធីជ្រមុជទឹក នៅកន្លែងសាធារណៈ ឬ នៅកន្លែងដែលស្ងាត់?

ម៉ាថាយ ៣:៥, ១៣ ________________________________________

> ជាការសំខាន់ ដើម្បីកត់សម្គាល់ថា អស់អ្នកដែលបានទទួលបុណ្យជ្រមុជទឹកនៅក្នុងគម្ពីរសម្ពន្ធមេត្រីថ្មី ពួកគេត្រូវបានគេធ្វើភ្លាមៗ ឬ បន្ទាប់ពីការប្រកាសជំនឿលើព្រះយេស៊ូគ្រិស្ត ។

## ២. វាតំរូវអោយចូលរួមនៅក្នុងក្រុមជំនុំណាមួយនៅក្នុងតំបន់ ។

វាហាក់បីដូចជាពិធីបុណ្យជ្រមុជទឹក គឺជាសេចក្តីតម្រូវមួយ នៅក្នុងការប្តេជ្ញាចិត្ត ចូលរួមក្នុងក្រុមជំនុំក្នុងតំបន់ ។ *សូមមើលកិច្ចការ ២:៤១-៤២ ។*

## ៣. វាបញ្ជាក់ពីជីវិតថ្មីរបស់យើងជាមួយព្រះគ្រិស្ត ។

នៅពេលដែលយើងលិចចុះទៅក្រោមទឹក ខណៈទទួលបុណ្យជ្រមុជទឹក នោះគឺជា រូបភាពពីជីវិតចាស់របស់យើង ដែលត្រូវបានស្លាប់ជាមួយនឹងព្រះគ្រិស្ត។ រួចនៅពេលដែលយើងងើបចេញពីទឹកមកនោះ បញ្ជាក់ពីជីវិតថ្មីរបស់យើងដែលបានរស់ឡើងវិញនៅក្នុង ព្រះគ្រីស្ទដែរ។ សូមអានរ៉ូម ៦: ៣-៥។ ហេតុនោះហើយ យើងកំពុងតែបង្ហាញដល់អ្នកដទៃថា យើងបានស្លាប់ហើយ (ដាក់នៅខាងក្រោយ) ផ្លូវចាស់របស់យើងដែលរស់នៅដោយគ្មានព្រះគ្រិស្ត ហើយឥឡូវនេះ យើងសុខចិត្តរស់នៅក្នុងជីវិតថ្មីជាមួយព្រះគ្រីស្ទ ។ ការយល់ដឹងនេះរីកលូតលាស់ឡើង នៅពេលដែលយើងបន្តជីវិតរបស់យើង រស់នៅក្នុងព្រះគ្រិស្ត ។

# សេចក្តីសន្និដ្ឋាន



នៅក្នុងពិធីជ្រមុជទឹក មនុស្សម្នាក់កំពុងតែឈរជាសាធារណៈ នៅចំពោះព្រះជាម្ចាស់។ គាត់ធ្វើការប្រកាសថា ជីវិតរបស់គាត់បានស្លាប់នៅក្នុងផ្លូវចាស់ ហើយកំពុងស្វែងរកការរស់នៅក្នុងជីវិតថ្មីជាមួយព្រះគ្រិស្ត! សូមកុំភ្ញាក់ផ្អើលឡើយ ប្រសិនបើបន្ទាប់ពីការសម្រេចចិត្តទទួលពិធីជ្រមុជទឹករបស់លោកអ្នកជួប នូវការជ្រួលច្របល់ ។ ដែលជាការសម្រេចចិត្តដ៏ពិបាកបំផុតដែលខ្ញុំធ្លាប់ធ្វើ។ មនុស្សខ្លះក៏មានបទពិសោធន៍ទទួលការល្បួងល ក្រោយពីការទទួលពិធីជ្រមុជទឹករួចដែរ។ អារក្សសាតាំងអាចនឹងសាកល្បងលោកអ្នក ដូចជាវាបានល្បួងល ព្រះយេស៊ូដូច្នោះដែរ សូមមើលនៅក្នុងគម្ពីរ ម៉ាថាយ ៤:១ ។

ប្រសិនបើលោកអ្នកជាអ្នកជឿ សូមរៀបចំសម្រាប់ការទទួលពិធីជ្រមុជទឹកឥឡូវនេះចុះ។ សូមទំនាក់ទំនងគ្រូគង្វាលរបស់លោកអ្នក ឬ អ្នកដឹកនាំគ្រិស្តបរិស័ទណាម្នាក់ដោយការឈ្លាសវៃ ។ សូមធ្វើការនោះចុះ ហើយព្រះជាម្ចាស់ នឹងប្រទានពរដល់លោកអ្នកជាមិនខាន!